■改編自：新北市教育局
陪你快樂學東埔寨語
□自編_

111 年新北市各級學校東南亞語文競賽
團體朗讀文稿東埔寨 國高中組 B-1

# ទៅផ្ទះយាយ

សុខានិងម៉ាក់ បងស្រី ប្អូនស្រី ជិះយន្តហោះទៅផ្ទះយាយប្រទេសកម្ពុជាទាំងអស់គ្នា។

សុខា: ម៉ាក់តើប្រទេសកម្ពុជាមានមធ្យោបាយធ្វើដំណើរអ្វីខ្លះ?

ម៉ាក់: នៅប្រទេសកម្ពុជាមធ្យោបាយធ្វើដំណើរខុសគ្នាពីតៃវ៉ាន់

សុខា: តើខុសគ្នាដូចម្ដេច?

ម៉ាក់: នៅជនបទប្រទេសកម្ពុជាមានរទេះសេះ រទេះគោ ម៉ូតូនិង ម៉ូតូតុកតុក។

បងស្រី: តើចំណែកឯនៅក្នុងទីក្រុងវិញនោះ?

ម៉ាក់: ឥឡូវក្នុងទីក្រុងនៅមានម៉ូតូ ប៉ុន្តែមានឡាន និង ម៉ូតូតុកតុកច្រើនជាង។

ប្អូនស្រី: អញ្ចឹងតើពួកយើងត្រូវជិះឡានអ្វីទៅផ្ទះយាយ?

ម៉ាក់: ពួកយើងជិះឡានក្រុងទៅ។

ម៉ាក់: ហើយនៅរយៈមួយម៉ោងទៀត ទើបឡានមកដល់។ អ្នកទាំងអស់គ្នាទៅញ៉ាំគុយទាវសិនទៅ។

សុខា:  ខ្លិនខ្ទិះដូងឈ្ងុយណាស់ណ៎ា  ខ្ញុំញុំាបន្ថែមនំបញ្ចុកសម្លរខ្មែរថែម
មួយចានទៀត។

បងស្រីប្អូនស្រី:  អញ្ចឹងពួកយើងញុំាបន្ថែមនំប៉ុងដាក់សាច់ដែលមានរស់
ជាតិឈ្ងុយឆ្ងាញ់ទៀត។ញុំារួច មុនដំបូងជិះឡានក្រុងផ្លូវឆ្ងាយទៅ
បន្ទាប់មកដូរទៅជិះម៉ូតូតុកតុកទៀត  ទើបបានដល់ផ្ទះយាយ។

សុខា:  ផ្ទះតាជាផ្ទះប្រក់គ្បឿងបុរាណបីខ្នងជាប់គ្នា តើចុះផ្ទះយាយជាផ្ទះ
ប្រភេទណាដែរ?

ម៉ាក់:   ផ្ទះដែលយាយស្នាក់នៅជាប្រភេទផ្ទះឈើខ្មែរបុរាណ។

ប្អូនស្រី: ម៉ាក់តើផ្ទះឈើខ្មែរបុរាណជាអ្វី?

បងស្រី:  ខ្ញុំដឹង  ផ្ទះឈើខ្មែរបុរាណជាផ្ទះដែលសាងសង់មានលក្ខណៈ
ពិសេស ធ្វើអំពីឈើ មនុស្សរស់នៅខាងលើ ឯខាងក្រោមដាក់
ឥវ៉ាន់។

សុខា:  ផ្ទះឈើខ្មែរបុរាណមួយខ្នងខាងមុខនោះជាផ្ទះយាយមែនទេ?

ម៉ាក់:   ពិតមែនហើយ យាយកំពុងតែបក់ដៃមក។

បងស្រី សុខា ប្អូនស្រី:ជំរាបសួរយាយ ពួកខ្ញុំនឹកយាយខ្លាំងណាស់!

យាយមើលមកពួកយើង ក្នុងទឹកមុខញញឹមប្រកបដោយព្រហ្មវិហារធម៌។

ទៅផ្ទះយាយពិតជាល្អមែន។